# សេចក្តីថ្លែងការណ៍រួម
# បញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាននៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤

ក្នុងទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន អង្គការសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ចាត់វិធានការឱ្យបានឆាប់រហ័ស និងជាក់លាក់ ដើម្បីធានានូវការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាព ចំពោះឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដែលបានប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

យោងតាមកំណត់ត្រាដែលបានចងក្រងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា យ៉ាងហោចណាស់អ្នកសារព័ត៌មានចំនួន<u>១៥នាក់ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា</u>ចាប់តាំងពីឆ្នាំ១៩៩៤ មក ហើយពួកគេនៅមិនទាន់ទទួលបានយុត្តិធម៌នៅឡើយ។ ក្នុងចំណោមនោះ អ្នកសារព័ត៌មានចំនួន១២នាក់បានរាយការណ៍អំពីបញ្ហារសើបមុនពេលពួកគេត្រូវបានសម្លាប់។

ការឃាំឃី និងការគំរាមកំហែង លើអ្នកសារព័ត៌មាននៅតែជាក្តីបារម្ភនៅឆ្នាំ២០២៤នេះ។ យោងតាម <u>សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា</u> (ខេមបូចា) អ្នកសារព័ត៌មាន ចំនួន ៤៦នាក់ បានរងការឃាំឃីក្នុងរយៈពេល០៩ខែ ក្នុងឆ្នាំ២០២៤ (ពីខែមករា ដល់ ខែកញ្ញា ឆ្នាំ២០២៤)។ ក្នុងចំណោមអ្នកសារព័ត៌មានទាំង៤៦នាក់នេះ មានអ្នកសារព័ត៌មាន ៣៤នាក់ប្រឈមនឹងការឃាំឃីតាមផ្លូវតុលាការដែលរួមបញ្ចូល ការកោះហៅមកសាកសួរ ការកោះហៅមកបង្ហាញខ្លួននៅតុលាការ និងការឃាត់ខ្លួន។ បន្ថែមពីនេះ អ្នកសារព័ត៌មានចំនួន៧នាក់រងនូវការបៀតបៀនលើរាងកាយ និងអ្នកសារព័ត៌មានចំនួន៥នាក់ទៀតប្រឈមនឹងការរឹតត្បិតក្នុងការបំពេញការងាររបស់ខ្លួន។ អាជ្ញាបណ្ណសារព័ត៌មានចំនួន៣ ត្រូវបានដកហូត។ ជាលទ្ធផល អង្គការអ្នកសារព័ត៌មានគ្មានព្រំដែនបានចាត់ថ្នាក់ប្រទេសកម្ពុជានៅលេខ១៥១ ក្នុងចំណោម១៨០ប្រទេសនៅក្នុងឆ្នាំ២០២៤ ហើយចំណាត់ថ្នាក់នេះបង្ហាញថាស្ថានភាពនៃសេរីភាពសារព័ត៌មានគឺមិនល្អ។

ការដៅមុខសញ្ញាលើអ្នកសារព័ត៌មាន ជាពិសេសអ្នកដែលកំពុងរាយការណ៍លើប្រធានបទសិទ្ធិមនុស្ស ធ្វើឱ្យប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ និងសារព័ត៌មាន បង្កជាការគំរាមកំហែងដល់ការទទួលបានព័ត៌មានរបស់សាធារណជន។ ការឃាំឃី និងការធ្វើទុក្ខបុកម្នេញនេះកាន់តែបង្កផលលំបាកថែមទៀត ក្នុងការនាំឱ្យបុគ្គលមានអំណាចទទួលខុសត្រូវចំពោះកំហុសរបស់ខ្លួន។ នៅពេលដែលអាជ្ញាធរមិនបានធ្វើការស៊ើបអង្កេតត្រឹមត្រូវ និងផ្តន្ទាទោសអ្នកប្រព្រឹត្តលើអ្នកសារព័ត៌មានជាសារមួយបង្ហាញថា បទល្មើសបែបនេះត្រូវបានអនុញ្ញាត ។

និទណ្ឌភាពចំពោះបទឧក្រិដ្ឋបែបនេះ មិនមែនកើតមានចំពោះតែទៅលើការវាយប្រហារលើអ្នកសារព័ត៌មានប៉ុណ្ណោះទេ។ កង្វះខាតនូវការស៊ើបអង្កេត និងនីតិវិធីព្រហ្មទណ្ឌត្រឹមត្រូវក្នុងករណីឃាតកម្មលើសកម្ម

ជនបរិស្ថាន លោក ឈុត វុទ្ធី សកម្មជនសហជីព លោក ជា វិជ្ជា និងលោក រស់ សុវណ្ណារ៉េត អ្នកវិភាគនយោបាយ លោកបណ្ឌិត កែម ឡី កាន់តែបង្ហាញពីការរីករាលដាលនៃវប្បធម៌និទណ្ឌភាពដែលមាននៅក្នុងប្រទេសកម្ពុជាបន្ថែមទៀត។ ករណីរៀបរាប់ខាងលើគ្រាន់តែជាផ្នែកមួយនៃករណីជាច្រើនទៀតនៃការរំលោភបំពានលើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សមាជិកនយោបាយជំទាស់ សហជីព និងសកម្មជនផ្សេងៗទៀតដែលករណីពួកគេមិនត្រូវបានដោះស្រាយពីសំណាក់ស្ថាប័នដែលមានតួនាទីការពារសិទ្ធិមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។

ដូច្នេះ យើងខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលឱ្យធ្វើការស៊ើបអង្កេតដោយឯករាជ្យទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។ ការស៊ើបអង្កេតទាំងនេះត្រូវតែប្រព្រឹត្តទៅដោយឆាប់រហ័ស និងស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលរួមបញ្ចូលទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ផែនការសកម្មភាពនៃអង្គការសហប្រជាជាតិស្តីពីសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងបញ្ហានិទណ្ឌភាព និងគោលការណ៍សម្រាប់ការពារ និងលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាពប្រឆាំងនិទណ្ឌភាព ដែលក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិបានធ្វើបច្ចុប្បន្នភាព។

យើងខ្ញុំសូមទាមទារយុត្តិធម៌សម្រាប់អ្នកទាំងឡាយណាដែលសិទ្ធិរបស់គេមិនត្រូវបានអើពើ។ រដ្ឋាភិបាលកម្ពុជាត្រូវតែថ្កោលទោស និងបញ្ចប់នូវនិទណ្ឌភាពចំពោះឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។

**សេចក្តីថ្លែងការណ៍នេះចូលរួមគាំទ្រដោយ៖**

១. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
២. សហព័ន្ធសហជីពកម្ពុជា(CATU)
៣. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)
៤. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
៥.សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(សមាគមអាដហុក)
៦.មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់)
៧.វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
៨. Centre for Independent Journalism (CIJ) Malaysia
៩.គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(COMFREL)
១០.សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
១១.អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)
១២.សមាគមបណ្តាញយុវជនកម្ពុជា(CYN)
១៣.សហព័ន្ធសហជីពសេរីឯករាជ្យ (FUFI)
១៤.សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)

១៥.គិរីផ្ទួសខ្មែរ
១៦.សហព័ន្ធអន្តរជាតិនៃអ្នកសារព័ត៌មាន(IJF)
១៧.សហព័ន្ធសហជីពឯករាជ្យ (INTUFE)
១៨.សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើលដ៍ (LRSU)
១៩.អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ(PED)
២០.អង្គការសមាគមជាងត្នោត(STT)
២១. The Alliance of Independent Journalists (AJI) Indonesia